## សេចក្តីអធិប្បាយសង្ខេបស្តីពី

# អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារក្យូតូ និងយន្តការអភិវឌ្ឍន៍ស្អាត

(The Climate Change Convention, The Kyoto Protocol and The Clean Development Mechanism (CDM))

## ១. សេចក្តីផ្តើម

ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំទី ៨០ មក គេបានរកឃើញភ័ស្តុតាងវិទ្យាសាស្ត្រជាច្រើន ដែលអះអាងថា សកម្មភាពរបស់មនុស្ស ជាមូលហេតុចំបងនៃការប្រែប្រួលអាកាសធាតុមិនប្រក្រតី នាប៉ុន្មានទសវត្សចុងក្រោយនេះ ។ ប្រសិនបើនិន្នាការប្រែប្រួលអាកាសធាតុនេះនៅតែបន្តទៀត នោះនាពេលអនាគតពិភពលោកនឹងជួបប្រទះនូវកំណើនកំដៅ ការឡើងកំពស់ទឹកសមុទ្រ ការប្រែប្រួលរបបទឹកភ្លៀង និងព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតីជាច្រើនទៀត (ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះសង្ឃរា ។ល។) ដែលអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់គ្រប់វិស័យសេដ្ឋកិច្ច ជាពិសេសវិស័យកសិកម្ម រុក្ខកម្ម ធនធានទឹក សុខាភិបាល បរិស្ថាន និងការលិចលង់តំបន់ទំនាបតាមឆ្នេរសមុទ្រជាដើម ។ ប្រទេសក្រីក្រជាអ្នកងាយរងគ្រោះជាងគេពីការប្រែប្រួលអាកាសធាតុ ដោយសារតែបណ្តាប្រទេសទាំងនោះភាគច្រើនជាប្រទេសកសិកម្ម ហើយមានសមត្ថភាព មធ្យោបាយ និងធនធានស្ទួចស្ទើងបំផុត សំរាប់ចាត់វិធានការឆ្លើយតបទៅនឹងបញ្ហានេះ ។

## ២. ការឆ្លើយតបរបស់មនុស្សជាតិ

### ២.១ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ

ដោយយល់យ៉ាងច្បាស់ពីផលវិបាកដ៏ធ្ងន់ធ្ងរទាំងនេះ បណ្តាប្រទេសនៅលើពិភពលោកបានឯកភាពគ្នាអនុម័តនូវ **អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ** (United Nations Framework Convention on Climate Change, UNFCCC) នៅក្នុងសន្និសីទកំពូលពិភពលោករបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានប្រព្រឹត្តទៅ នៅខែ មិថុនា ឆ្នាំ ១៩៩២ នាទីក្រុង រីយ៉ូដឺសានេរ៉ូ នៃប្រទេសប្រេស៊ីល ។

គោលបំណងសំខាន់នៃអនុសញ្ញានេះ គឺធ្វើឱ្យកំហាប់ឧស្ម័នផ្ទះកញ្ចក់ [1] (greenhouse gases) នៅក្នុងបរិយាកាសមានស្ថេរភាពនៅក្នុងកំរិតមួយ ដែលអាចរាំងស្កាត់នូវឥទ្ធិពលប្រកបដោយគ្រោះថ្នាក់បណ្តាលមកពីសកម្មភាពមនុស្សទៅលើប្រព័ន្ធអាកាសធាតុ ។

មកទល់បច្ចុប្បន្ន មានប្រទេសចំនួន ១៨៦ នៅលើពិភពលោក បានចូលជាសមាជិកនៃអនុសញ្ញានេះ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខា សុំចូលជាសមាជិកនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៩៥ ហើយនៅថ្ងៃទី ២៤ តុលា ឆ្នាំ ១៩៩៦ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ។

### ២.២ ពិធីសារក្យូតូ

**ពិធីសារក្យូតូ** (The Kyoto Protocol) គឺជាកិច្ចព្រមព្រៀងទីមួយនៅក្រោមអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានកំណត់គោលដៅជាក់លាក់ ក្នុងការឈានទៅសំរេចគោលដៅចំបងនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅក្នុងប្រទេសអភិវឌ្ឍន៍ ។ ពិធីសារក្យូតូត្រូវបានអនុម័តដោយសមាជិកនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងកិច្ចប្រជុំរបស់ភាគីជាសមាជិកលើកទី ៣ ដែលបានប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី ១ ដល់ ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ នៅទីក្រុងក្យូតូ ប្រទេសជប៉ុន ។ ពិធីសារនេះត្រូវបានដាក់ឱ្យចុះហត្ថលេខាចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ

---

[1] ឧស្ម័នផ្ទះកញ្ចក់សំខាន់ៗមាន : ឧស្ម័នកាបូនិច ($CO_2$) មេតាន ($CH_4$) ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$) ។ល។

១៩៩៨ ដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ នៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក ។ មកទល់ចុងខែមករា ឆ្នាំ ២០០៣ មានប្រទេសចំនួន ១០០ បានផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារនេះរួចហើយ ។ ពិធីសារនេះនឹងចូលជាធរមាន នៅក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយពីពេលដែលប្រទេសចំនួន ៥៥ ផ្តល់សច្ចាប័ន ឬចូលជាសមាជិក ដោយរួមទាំងប្រទេសក្នុងឧបសម្ព័ន្ធទី ១ ផង (ពោលគឺក្រុមប្រទេសមានឧស្សាហកម្មលូតលាស់ និងប្រទេសមានសេដ្ឋកិច្ចស្ថិតនៅក្នុងអន្តរកាល ជាអតីតប្រទេសក្នុងប្លុកសង្គមនិយម) ដែលបានបញ្ចេញឧស្ម័នកាបូនិចចំនួន ៥៥% នៃបរិមាណបញ្ចេញសរុបនៅឆ្នាំ ១៩៩០ ។ ពិធីសារនេះគឺជាជំហានដាក់ស្តែងទី ១ ដែលអាចជួយពិភពលោក ឈានទៅសំរេចបាននូវគោលដៅចុងក្រោយនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ គឺការរាំងស្កាត់ "ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់បណ្តាលពីសកម្មភាពមនុស្សចំពោះប្រព័ន្ធអាកាសធាតុ" ។ យោងតាមពិធីសារនេះ ប្រទេសចំនួន ៣៨ នៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញា បានយល់ព្រមបំពេញកាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ប្រាំមួយមុខ ក្នុងបរិមាណយ៉ាងហោចណាស់ចំនួន ៥% ធៀបនឹងកំរិតដែលប្រទេសទាំងនោះបានបញ្ចេញនៅឆ្នាំ ១៩៩០ នៅរវាងឆ្នាំ ២០០៨-២០១២ ។ បណ្តាប្រទេសទាំងនេះអាចធ្វើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលជាកាតព្វកិច្ចរបស់ខ្លួន តាមរយៈយន្តការបី គឺ : (១) ការធ្វើពាណិជ្ជកម្មអេមីស្យុង (Emission Trading), (២) ការអនុវត្តន៍រួមគ្នា (Joint Implementation, JI) រវាងប្រទេសអភិវឌ្ឍន៍ដូចគ្នា និង (៣) យន្តការអភិវឌ្ឍន៍ស្អាត (Clean Development Mechanism, CDM) សំដៅលើកទឹកចិត្តឱ្យមាន គំរោងកាត់បន្ថយការបញ្ចេញឧស្ម័នរួមគ្នារវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ។

## ២.៣ យន្តការអភិវឌ្ឍន៍ស្អាត (The Clean development Mechanism, CDM)

កាលានុវត្តភាពសំខាន់របស់ពិធីសារក្យូតូសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ គឺការចូលរួមអនុវត្តគំរោងក្រោម " **យន្តការអភិវឌ្ឍន៍ស្អាត** " ដែលមានបំនងជួយប្រទេសកំពុងអភិវឌ្ឍន៍ ឱ្យសំរេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព និងជួយប្រទេសនៅក្នុងឧបសម្ព័ន្ធទី ១ ក្នុងការសំរេចនូវកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន ។ បណ្តាគំរោងនេះរួមមាន :

១. គំរោងលើកកំពស់ប្រសិទ្ធិភាពថាមពល និងការសន្សំសំចៃថាមពល នៅក្នុងវិស័យឧស្សាហកម្ម ការដឹកជញ្ជូន ការផលិតថាមពល និងលំនៅដ្ឋាន

២. គំរោងប្រើប្រាស់ថាមពលកើតឡើងវិញ (renewable energy) ដូចជាពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ថាមពលជីវៈម៉ាស (biomass)

៣. គំរោងស្តារព្រៃឈើ (reforestation) និងដាំដើមឈើនៅតំបន់ថ្មីៗ (afforestation) ។ល។

ប្រទេសលូតលាស់ជាច្រើន ដែលមានកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួននោះ បានចាប់អារម្មណ៍ក្នុងការចូលរួមអនុវត្តន៍គំរោងក្រោម "យន្តការអភិវឌ្ឍន៍ស្អាត" នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាកម្ពុជាជាដើម ដោយហេតុថា ប្រទេសជឿនលឿនទាំងនោះមានការលំបាក ក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសគេផ្ទាល់ ពីព្រោះគេបានប្រើប្រាស់បច្ចេកវិជ្ជាថ្មី និងទំនើប ប្រកបដោយប្រសិទ្ធិភាពខ្ពស់រួចទៅហើយ ។ ដោយយល់យ៉ាងច្បាស់ពីកាលានុវត្តភាពដែលពិធីសារក្យូតូអាចផ្តល់ឱ្យប្រទេសជាតិ និងពីកាតព្វកិច្ចក្នុងការរួមចំណែកជាមួយសហគមន៍អន្តរជាតិក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើលិខិតូបករណ៍សុំចូលជាសមាជិកនៃពិធីសារក្យូតូ កាលពីថ្ងៃ ទី ៤ ខែ កក្កដា ឆ្នាំ ២០០២ ដែលអនុញ្ញាតឱ្យកម្ពុជានូវសិទ្ធិអនុវត្តបណ្តាគំរោងក្រោម " យន្តការអភិវឌ្ឍន៍ស្អាត " នេះ ។

# ៣. កម្ពុជា និងបញ្ហាប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ ១៩៩៥ ពោលគឺតែក្នុងរយៈពេលពីរឆ្នាំ ក្រោយពីការបង្កើតរដ្ឋាភិបាល ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយសេរីជាលើកទីមួយ ។ នៅឆ្នាំ ១៩៩៨ មូលនិធិបរិស្ថានពិភពលោក (Global Environmental Facility, GEF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme, UNDP) បានអនុម័តផ្តល់ជំនួយចំនួន ៣២ ម៉ឺនដុល្លារអាមេរិច ដើម្បីឱ្យកម្ពុជារៀបចំរបាយការណ៍ជាតិលើកទីមួយរបស់ខ្លួន សំរាប់ដាក់ជូនសម័យប្រជុំប្រចាំឆ្នាំនៃភាគីជាសមាជិករបស់អនុសញ្ញា ។ យើងបានប្រើប្រាស់ជំនួយនេះសំរាប់ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាលើកដំបូងនៅកម្ពុជា ដែលបានកំណត់ឃើញថា នៅឆ្នាំ ១៩៩៤ ប្រទេសកម្ពុជាបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចំនួនប្រមាណ ៦០

លានតោន ហើយព្រៃឈើយើងស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស ចំនួនប្រមាណ ៦៥ លានតោន ។ គំរោងនេះគឺជាជំហានជាក់ស្តែងទីមួយនៃការអនុវត្តន៍អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

ពិតមែនតែកិច្ចការប្រែប្រួលអាកាសធាតុពុំមែនជាទិសដៅពិសេសដោយឡែករបស់រាជរដ្ឋាភិបាលក្តី ក៏បណ្តាសកម្មភាព និងវិធានការជាច្រើនរបស់រាជរដ្ឋាភិបាល បានរួមចំណែកនៅក្នុងកិច្ចប្រឹងប្រែងជាសកល សំដៅសំរេចបាននូវគោលដៅនានារបស់អនុសញ្ញា ។ បណ្តាកិច្ចប្រឹងប្រែងទាំងនេះរួមមានគោលនយោបាយ និងសកម្មភាពគំរោងនានា នៅក្នុងវិស័យព្រៃឈើ និងថាមពល ដូចជាការបង្កើត និងគ្រប់គ្រងតំបន់ការពារធម្មជាតិចំនួន ២៣ ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ១៨% នៃផ្ទៃប្រទេស ការរៀបចំបណ្តាបិធានច្បាប់នានាទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុល កិច្ចប្រឹងប្រែងបច្ចុប្បន្នសំដៅលុបបំបាត់ការកាប់ឈើ និងការជួញដូរសត្វព្រៃខុសច្បាប់ ព្រមទាំងសកម្មភាពរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍន៍ថាមពលកើតឡើងវិញ និងបច្ចេកវិជ្ជាស្អាត ហើយមានប្រសិទ្ធិភាពខ្ពស់ នៅក្នុងវិស័យថាមពល ។

ព្រះរាជាណាចក្រកម្ពុជាបានគាំទ្រយ៉ាងសកម្ម ដល់ការជំរុញអនុវត្តពិធីសារក្យូតូឱ្យបានឆាប់តាមដែលអាចធ្វើបាន សំដៅរៀបចំនូវមូលដ្ឋានគ្រឹះដំបូងឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ដូចដែលសម្តេចនាយករដ្ឋមន្រ្តី **ហ៊ុន សែន** ធ្លាប់បានមានប្រសាសន៍នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្រ្តីបរិស្ថានប្រទេសអាស៊ាននៅទីក្រុងភ្នំពេញ កាលពីខែឧសភា ឆ្នាំ ២០០១ ក៏ដូចជានៅក្នុងកិច្ចប្រជុំកំពូលមហាអនុតំបន់ទន្លេមេគង្គលើកទី ១ កាលពីចុងឆ្នាំ ២០០២ នៅក្រុងភ្នំពេញ និងក្នុងឱកាសបើកកិច្ចប្រជុំឆ្នាំបរិស្ថានអាស៊ាន ២០០៣ នៅអង្គរវត្ត កាលពីដើមខែមីនា ឆ្នាំ ២០០៣ ថ្មីៗនេះ ។

ប្រទេសកម្ពុជាក៏បានគាំទ្រផងដែរក្នុងការដាក់បញ្ចូលព្រៃឈើ ជាអាងផ្ទុកកាបូន ក្នុងគោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្រោមពិធីសារក្យូតូ ដែលជាការលើកទឹកចិត្តជំរុញឱ្យមានការថែរក្សាព្រៃឈើនៅលើពិភពលោក ។ កម្ពុជាបានស្នើឡើងថា ចាំបាច់ត្រូវពិចារណាលើតួនាទីរបស់ព្រៃឈើនៅក្នុងបរិបទដ៏ទូលំទូលាយមួយ គឺពុំត្រឹមតែជាភ្នាក់ងារសំអាតបរិយាកាសប៉ុណ្ណោះទេ ប៉ុន្តែត្រូវពិនិត្យលើពហុប្រយោជន៍ច្រើនយ៉ាងផ្សេងទៀតរបស់ព្រៃឈើ ទាំងផ្នែកសេដ្ឋកិច្ច បរិស្ថាន ក៏ដូចជាការជួយសំរាលគ្រោះធម្មជាតិនានា ដូចជាគ្រោះទឹកជំនន់ និងព្យុះជាដើម ។ លើសពីនេះ ការប្រើប្រាស់ព្រៃឈើជាអាងផ្ទុកកាបូនក៏អាចចូលរួមចំណែកក្នុងកិច្ចការពារព្រៃឈើ សំរាប់ផលប្រយោជន៍ និងសេវាកម្មបរិស្ថានជាច្រើនទៀតផងដែរ ។ ទោះជាយ៉ាងណាក្តី ភាគចំណែកនៃធនធានដែលត្រូវយកមកប្រើសំរាប់កែលំអអាងផ្ទុកកាបូន ពុំត្រូវធ្វើឱ្យមានការខូចខាតដល់កិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័ន តាមរយៈការជំរុញការប្រើប្រាស់ថាមពលកើតឡើងវិញ ប្រសិទ្ធិភាពថាមពល និងការផ្ទេរបច្ចេកវិជ្ជាទៅឱ្យប្រទេសក្រីក្រឡើយ ។ ប្រទេសកម្ពុជាចាត់ទុកថា សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ណាមួយ ត្រូវតែផ្តល់ឱកាសដល់ បណ្តាប្រទេសទាំងនោះ ក្នុងការសំរេចបាននូវគោលដៅអភិវឌ្ឍន៍នានារបស់ខ្លួន ។

## ៤. ការលានុវត្តភាពដែលកម្ពុជាអាចទទួលបានពីពិធីសារក្យូតូ

សំរាប់កម្ពុជា ការចូលជាសមាជិករបស់ពិធីសារនេះ អាចនឹងនាំមកនូវសារៈប្រយោជន៍ច្រើនយ៉ាង ដូចជា :

១. ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ កម្ពុជាពុំមានជាប់កាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ទេ

២. ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ ពុំតំរូវឱ្យកម្ពុជាបង់ជាវិភាគទាន ឬចំណាយណាមួយឡើយ

៣. ទទួលផលចំណេញផ្នែកនយោបាយ :

- បង្ហាញពីសុច្ឆនៈ និងការប្តេជ្ញាចិត្ត ក្នុងការរួមចំណែកជាមួយសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- លើកកំពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំដែលរៀបចំឡើងសំរាប់ពិភាក្សាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

៤. ទទួលផលចំណេញផ្នែកបរិស្ថាន :

- រួមចំណែកដោះស្រាយបញ្ហាអាកាសធាតុមិនប្រក្រតីនៅកម្ពុជា ព្រោះអាកាសធាតុកម្ពុជាមិនអាចកាត់ផ្តាច់ពីអាកាសធាតុពិភពលោកបានឡើយ

- អាចទទួលជំនួយពីប្រទេសអ្នកមាន និងអង្គការអន្តរជាតិនានា សំរាប់បណ្តាគំរោងទប់ស្កាត់ការបំពុលបរិយាកាសនៅទីក្រុង កិច្ចការពារព្រៃឈើ ការដាំដើមឈើឡើងវិញ ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី ការរៀបចំផែនការបន្ស៊ាំ (adaptation plan) ទៅនឹងការប្រែប្រួលអាកាសធាតុ ។ល។

៥. ទទួលបានផលចំណេញផ្នែកសេដ្ឋកិច្ច ៖

- អាចចូលរួមក្នុងការអនុវត្តន៍គំរោងក្រោមយន្តការអភិវឌ្ឍន៍ស្អាតទាក់ទងនឹង ៖ ការសន្សំសំចៃថាមពល ប្រសិទ្ធិភាពថាមពល បច្ចេកវិជ្ជាផលិតកម្មស្អាតដែលមិនបំផ្លាញបរិស្ថានក្នុងវិស័យឧស្សាហកម្ម ការអភិវឌ្ឍន៍ថាមពលកើតឡើងវិញ (renewable energy) គំរោងការពារនិងដាំព្រៃឈើ ការកែលំអវិស័យគមនាគមន៍ ។ល។
- ទទួលការគាំទ្រផ្នែកស្រាវជ្រាវ និងសង្កេតតាមដានអាកាសធាតុ ដែលមានសារៈសំខាន់បំផុតសំរាប់ប្រទេសកម្ពុជា ដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្ម
- ទទួលការគាំទ្រផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ។

ជារួម ការចូលជាសមាជិកនៃពិធីសារនេះ ពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់កម្ពុជាឡើយ ។ ផ្ទុយទៅវិញ វាគឺជាឱកាសដ៏ល្អមួយ ដែលអនុញ្ញាតឱ្យកម្ពុជាទទួលបាននូវផលចំណេញលើវិស័យជាច្រើន ដូចបានរៀបរាប់ខាងលើ ដែលជាទុនយ៉ាងសំខាន់សំរាប់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិ ឆ្ពោះទៅសំរេចបាននូវការអភិវឌ្ឍន៍ប្រទេសប្រកបដោយចីរភាព ។